# ការសម្ភាសរបស់អ្នកមីង យើន ស្រីម៉ៅ

**ក៖ អ្នកធ្វើការសម្ភាស មាស ចិន្តាពិសី ខ៖ អ្នកទទួលការសម្ភាស អ្នកមីងយើន ស្រីម៉ៅ**

ខ៖ ទៅរៀនក្រោកពីព្រឹកចឹងទៅទៅរៀន ដល់ម៉ោងដប់ឬដប់មួយបានចេញហើយទៅញាំបាយចឹងហា ដល់មកថ្ងៃយើងត្រូវទៅរៀនទៀតចឹងហា តែយើងទៅរែកដីសិន ទៅរែកដីតាំងពីម៉ោងបីថ្ងៃចឹងទៅរហូតដល់ម៉ោងប្រាំពីរព្រឹកបានត្រឡប់មកវិញ ទៅរៀនដល់ទៅរហូតដល់ថ្ងៃរសៀលចឹងទៅមកវិញរែកដីទៀតហា ដល់ម៉ោងប្រាំពីរព្រឹកមកវិញនាំគ្នាដើរមកវិញមក ហើយពេលគេចែកអំបិលបាយនិងគេចែកបាយតិចមកនិងអំបិលមួយគ្រាប់ ហើយយើងដើរចឹងទៅអត់ចឹងទៅយើងដើរបេះត្រកួន យើងក្តិចអាវែងៗនិងវាលោស់មកមានត្រួយហើយយើងយកមកឆាអត់មានខ្លាញ់ទេ ខ្លាញ់កណ្តុលចឹងណាយកមកឆាទៅជូនណាលាយអំបិលនិងមួយគ្រាប់និងអត់ដាក់ទាំងអស់ទេ យើងដាក់ពាក់កណ្តាលដុំទៅយើងទុកពាក់កណ្តាល៕

ក៖ នៅក្នុងសម័យនិង តើអ្នកមីងអាចចាំថាអ្នកមីងមានអាយុប៉ុន្មានឆ្នាំដែរទេ?

ខ៖ ប្រហែលដប់ពីរឆ្នាំ និងអត់មានឪពុកម្តាយទេណា ស្លាប់អស់ហើយ បងប្អូនក៏បែក ស្លាប់អស់ទៅ ចឹងបានថាជំនាន់នុងប្រហែកប៉ុននិងដប់ពីរឆ្នាំ ៕

ក៖ នៅក្នុងសម័យនិង នៅពេលដែរអ្នកមីងអត់មានឪពុកម្តាយចឹង តើអ្នកមីងទៅរស់នៅជាមួយអ្នកណាគេដែរ?

ខ៖ នៅជាមួយបងមួយចឹងទៅ បងៗគេបែកហើយនៅជាមួយបងមួយនិងនៅផ្ទះយើងនិង ពេលយើងឈឺស្កាត់ចឹងទៅយើងមានអ្នកជិតខាង គេជួយមើលយើងទៅណាយើងទៅរកគាត់ទៅ យើងដេកមួយគាត់ចឹងទៅជួនកាលទៅយើងដេកនៅផ្ទះយើងចឹងទៅ ដល់ម៉ោងប្រាំចឹងទៅយើងចេញអត់បានទេព្រោះឆ្កែចចក ផ្ទះទាបដែរប៉ុននិងធ្វើពីរជាន់តែមួយខ្ពស់ជាងនិងមួយតែមួយទៀតប៉ុននិងមួយ ផ្ទះនិងលោកធ្វើអោយ កន្លែងណាដែររហៀកចឹងទៅនាំពីរនាក់បងប្អូននិងជួសជុលេពុរនាក់បងប្អូនចឹងទៅ ហើយដំបូលនោះបេះដូងធ្លាក់មកនៅវាធ្លុះមួយជំហៀង មានមួយជំហៀងអត់មួយជំហៀង បើខាងនេះអត់ដំបូលចឹងយើងដេកមកខាងនេះមក ដេកពីរនាក់បងប្អូននិង និយាយទៅកាលជំនាន់ប៉ុលពតនិងពិបាកណាស់នាងអើយ អស់ម៉ែអស់អីទៅនៅតែពីរនាក់និង ដល់នៅទៅគេជម្លៀសអោយទៅនៅភូមិមួយទៀត ដល់ទៅនៅជាមួយបងចិញ្ចឹមនិងទៅមុនទៅ ចាស់ៗគេដោយទៅផ្សេងក្មេងៗគេអោយផ្សេង អត់អោយទៅជាមួយឪពុកម្តាយទេ ហើយខ្ញុំឡើងឡានទៅនិងគេចេះតែប្រានមកវិញ ឡើងទៅគេចេះតែប្រានមកវិញអា

ក្មេងៗគ្នាឯងនិងណា ដល់ពេលចឹងទៅតែកុងឡាននិងមាឌធំៗណាគេទាញយើងមកវិញថាកុំចូល អាឡានទាញកំរបបិទជិតឈឹង ដល់ពេលបិទជិតចឹងទៅគាត់ក៏ចាប់ទាញមកវិញ ហើយគាត់ឡើងទៅអោយទៅអង្គុយលើកាបីនលើហ៎ ពីរនាក់គាត់និងហើយបើកឡានចេញទៅភូមិពីបាត់ដំបងនិងទៅអញ្ចោះទៅវិញ ទៅខាងភូមិថ្មគោលចុះទៅលិចចឹងទៅ ចាក់ឈាងចុះទៅចុះពីភ្នំសំពៅទៅ ខាងលិចភូមិសែងត្រែង ហើយទៅដល់គេសួរថា អូនឯងដឹងទេថាពួកបងយកមីអូនឯងទៅណា ថាខ្ញុំអត់ដឹងផងបង មើលមកជិះឡានមើលមកមនុស្សចាស់ ប៉ុនៗកូនក្មេងលើដំបូងឡាននិងថាបង គេថាគេអោយបងយកពួកមីអូនឯងមកសម្លាប់ណា ហើយមីងនិងឡើងញ័រត្រត់ហើយ ប៉ុន្តែកុំខ្លាចព្រោះហួសកន្លែងសម្លាប់ហើយកន្លែងសម្លាប់និងកន្លែងក្បាលខ្មោច គេហៅកន្លែងក្បាលខ្មោចនិងហា ទៅពីកន្លែងក្បាលខ្មោចគេហៅកោះចំការចេកពីដើមហាពីសង្គមណា កោះចំការគេនិងហើយគេថាកុំភ័យមីអូនហួសកន្លែងសម្លាប់ហើយ បងមិនយកមីអូនឯងទៅសម្លាប់ទេ គាត់ហួសទៅទៅដល់ភូមិនុងដល់ទោដល់ទៅកន្លុកនិងហើយនងចិញ្ចឹមនិងគាត់ហៅទៅមុន គេថារកកន្លែងសម្រាកសិន ហើយខ្ញុំថាទៅមុនចុះ ខ្ញុំចាំប្អូនខ្ញុំពីរនាក់សិន ដល់ពេលចឹងចាំទល់តែព្រលប់មើល មើលគ្នាលេងចង់ដើញបានថាចុះពីលើឡាន

ចឹងទៅគាត់សួរចឹងទៅ គាត់ហៅឆ្លើយទៅបានទៅជាមួយគ្នានិង កត់ឈ្មោះកត់អីនៅភូមិនិងទៅទាំងអស់គ្នានិងទៅ នៅភូមិនិងរហូតបានប៉ុន្មានប្រហែលជាបានមួយខែ ពីរខែអីនិងហើយមីងនិងដំប៉ៅជើងនិងតែបន្តិចទេ គ្រូនិងគេអោយនៅមើលពួកក្មេងៗតូចៗកម្ពស់ៗនិង ហើយមានគេអ្នកច្រណែន ហើយគេថាលោកគ្រូមិត្តម៉ៅពេញក្រមុំដែរម៉េចបានមិនអោយចល័យ ហើយបានប្អូនខ្ញុំនិងគេថាឯងក៏ចេះដឹងម៉េស បើឯងអោយគាត់ទៅចល័ចអាញ់ក៏ទៅដែរ ដល់ពេលចឹងទៅបងមួយនិងក៏ទៅចល័ចទៅនៅតែមីងនិង បានចុះធ្វើការបានតែពីរថ្ងៃគត់រត់ចោលឆ្នាំងបាយ ពួកយួននិងរត់មក ហើយចុះបានពីរថ្ងៃនិង រត់មកត្រឡប់ត្រឡិនកាន់ចានបាយយកអាក្មួយនេះ ផ្ទះជិតគ្នានិងយករត់ទៅរត់មក ពិស្រែនិងមក គេអោយយើងទៅយើងពួកកុមារទៅរើសគួរស្រូវ និងជញ្ជូនគរជាមួយចាស់ៗនិងមក

ហើយចេះឆ្វល់ស្អីនិងដីហុយជុក គ្រាន់តែឮគ្រាប់ផ្លោងនិងរត់ចោលចានចោលឆ្នាំង ថាពួកនិងមកហើយយើងរត់ ដែលបងចិញ្ចឹមមីងនុង លេងអត់ទាន់ដឹងទេទៅលេងផ្ទះពូនៅភូមិងិតនុងទៅដល់មិនទាន់បានចូលផ្ទះគាត់និងឯណា ទៅដល់ប្រធានភូមិនុងគេចែកអង្ករចែកចានចែកឆ្នាំង ប្រជាជនគេនិងហើយមីងដណ្ដើមអង្ករគេនិងបានពីរតៅកន្លះ ស្ពាយដាក់សកដូរនិងមកយកមកផ្ទះនិងមក ទឹមគោទឹមរទេះបរចូលព្រៃ ដល់បរចូលព្រៃឯពួកប្រុសៗនិងគេបររទេះនិងទៅ រួចមីងនិងពីរនាក់បងចិញ្ចឹមនិងពរកូនតូចមួយនិង

កូនប្រហែលជាប៉ុន្មានប្រហែលជាមួយខួបចុះ បងចិញ្ចឹមនិងអោយមីង ពររត់តាមភ្លឺស្រូវនិងក

ម្តស់នេះ គ្រាន់តែឃើញនិងអាគ្រាប់ធំអាគ្រាប់តូចនិងទម្លាក់អង្ករចោល ដេកផ្ងាចឹងទៅរួចរត់មកទៀតមក បើគេថាអំស្រែកមកទៀតហើយក្រាបទម្លាក់អង្ករចោល ភ្លេចខ្លួនក្រាបទៅទៀតទៅភ្លឹកម្តស់និងម៉ាល្មមនិងបាំងខ្លួនយើងជិត ខំបន់ដូនបន់តា បន់ម៉ែបន់អីអស់ហើយបានរត់ចូលទៅ ក្នុងព្រៃចឹងទៅរត់ចូលទៅក្នុងប្រឡាយ ដេកនៅនិងបានមួយយប់ចឹងទៅបានព្រឹកឡើងបានបរទេះចូលមកផ្លូវថ្នល់វិញ ដល់បរមកផ្លូវថ្នល់វិញទៅ ហើយបានពួកអ្នកធ្វើការនៅថ្មគោលនិង ហើយគេសួរថាបរទេះទៅណា ខ្ញុំថានៅប្រកាច់យកស្អីទៀត នេអាពតរត់ខ្វាត់ខ្វាយអស់ហើយនេបរយកទេះយកអី ទៅស្រុកកំណើតហើយថាមែនអី អើយមែនតើពួកយួនចូលមកហើយចឹងបានពួកនិងរត់មកទៅអ្នកខ្លះបានអង្ករហ៉ាយបានដើរតាមផ្លូវថ្នល់និងមក មកទៅមកនៅឯបាត់ដំបងវិញមកទៅមកនៅវត្តនិងគេហៅថាវត្តរំដួល ហឹមខ្ញុំវេទនាណាស់ជំនាន់អាពតមិនស្រួលទេ យើងមិនហ៊ានលួចអីគេគ្រាន់តែដំណាំដៃរយើងដាំខ្លួនឯងនិង ចេកយើងដាំនៅមុខផ្ទះយើងចឹងហា ដំឡូងអីក៏ដោយអត់អោយយើងយកកាប់ស៊ីទេ គេយកទៅនិងគេអោយចុងស្និតមួយឬក៏ពីរស្និតមកវិញ និងគេអត់អោយយើងកាប់ស៊ីរបស់យើងអ្នកដាំសោះនិង ដាច់ខាតគេអត់អោយតែម្តង មីងទៅនៅភូមិនិងស្រួលម៉្យាងដែរដូចថា គេចែកអង្ករចែកស្រូវងោយស៊ីចឹងបីខែ ដល់ពេលតែផុតពីបីខែនិងទៅគេងោយយើងស៊ីរួមវិញហើយ តែស៊ីរួមមានកូនមានអីទៅយើងពិបាកណា ហើយមីងនិងមានពាងធំៗណាពាងយើងពីដើមនិង មីងសល់អង្គរនិងទៅមីងជីកដីពីរនាក់បងប្អូននិង កប់ក្នុងក្រោមពាងនិងដល់យប់ឡើងបាននាំគ្នាកៀយ ដល់យកមកទៅនាំគ្នាកិនធ្វើគុយទាវ ហើយឆ្នាំងយើងប៉ុនៗនិងយកមកលាបម្សៅពីលើទៅ លាប់ទៅដល់ឆ្អិតទៅបើកទៅយកដាក់ហាល ដាក់ហាលទុកហូបទៅយប់ៗ បបរចែករាវៗគ្មានឃើញគ្រាប់អង្ករមួយគ្រប់ទេ ដល់ពេលរួបចឹងទៅហើយមីងក៏មិនហ៊ានលួចរបស់អីគេដែរ ខ្លាចតែគេសម្លាប់ចោលតែប៉ុននិង៕

ក៖ នៅសម័យប៉ុលពតនិង តើគេបានជម្លៀសក្រុមគ្រួសាររបស់អ្នកមីងទៅរស់នៅក្នុងភូមិ ឃុំ ស្រុកអ្វីដែរ?

ខ៖ នៅភុមិបាត់ដំបង គេហៅថាភូមិស្តី ភូមិស្តីនិងចុះពីស្ពានបាត់ដំបងនិងមក មកអញ្ចេះវិញមកពីក្រោមមកវិញ គេហៅថាភូមិស្តីតែមិនដេងថាគេហៅខេត្តអីទេ ជំនាន់នុងយើងមិនដឹងទេណា មិនដឹងស្រុកណាខេត្តណាទេគ្រាន់ដឹងថាភូមិនិង ហើយដឹងត្រឹមថាខេត្តបាត់ដំបងតែប៉ុននិង៕

ក៖ ចុះចំណែកឯឪពុកម្តាយបងប្អូនរបស់អ្នកមីងវិញ តើពួកគាត់បានទៅរស់នៅភូមិឃុំអ្វីដែរ?

ខ៖ គាត់និងចាស់ៗនិងគេអោយទៅនៅតាមសមរភូមិ អត់អោយនៅភូមិទេព្រោះចេញទៅឆ្ងាយទៅ ចេញទៅរកត្រីអីនៅទន្លេសាបចឹងទោ បងស្រីមួយគាត់ទៅកងចល័ត នៅចឹងណាព្រោះយើងនៅភូមិកងចឹង ព្រោះយើងនៅកុមារប៉ុននិងក៏នៅកុមារដែរ ប៉ុន្តែនៅជំនាន់នុងនៅកុមារមិនមែនយើងអាយុច្រើនទេណា បើយើងអាយុច្រើនមែនតែតូចនិង យើងមាឌល្អិតដល់ទៅពេលពិបាកាំណស់នាងអើយរស់នៅអត់ពីឪពុកម្តាយទៅ ឪពុកមីងនិងគាត់ធ្វើជាងដែក ធ្វើកាំបិតធ្វើកណ្តៀវអោយគេចឹងទៅ ហើយដល់ពេលចឹងទៅគេអោយគាត់ទៅកាប់ ឈើអីអោយមកធ្វើដងកណ្តៀវចឹងគេទៅប្រើគាត់អោយទៅកាប់ រលស់ជាប់នៅព្រំវត្តនិង គាត់ថាគាត់អត់កាប់ទេរបស់និងរបស់នៅក្នុងវត្តចឹង តែងតែមានគេនៅហើយ អោយខ្ញុំទៅកាប់ឆ្ងាយក៏ខ្ញុំទៅដែរអោយទៅតែម្នាក់ឯងក៏ខ្ញុំទៅដែរ ទៅគេថាតាឯងកាប់ទៅ ហើយគាត់ក៏កាប់ដល់កាប់ទៅ ដូចថាគេធ្វើចឹងណាគេអ្នកខាងផ្លូវងងឹត ដល់គេធ្វើទៅគាត់ចេះតែចុកចាប់ឈឺក្អួតឈាមម៉ែមីងនិងក៏ទៅរកគេមើលទៅ ដល់ទៅគេថាគាត់មានប៉ះពារជាមួយគេ នៅជិតវត្តនិង ចាសត្រូចហើយទៅអុចធុកនិយាយៗដឹងថាគេមកយក គេមកយកគាត់បានប៉ុន្មានថ្ងៃក៏ស្លាប់ទៅ ស្លាប់ទៅនិងគាត់បានក្តានិងបានក្តាគងប្លាគេពីដើម ដល់គាត់ទៅយកមកបានអោយគេធ្វើក្តារយកដាក់អោយគាត់ហើយបានយកទៅកប់ យកទៅកប់ចឹងទៅនៅក្នុងព្រៃឆ្ងាយណាស់ ឆ្ងាយពីភូមិដល់ទៅពេលបានមក ស្លាប់បានប៉ុន្មានប្រហែកបីបួនខែ មិនដឹងទេនេះឪពុកមីងនិងគាត់ស្លាប់ខែ១១ថ្ងៃ១១ដែរ ចំខែកត្តិកដល់គាត់ស្លាប់ទៅពិបាកវេទនាណាស់ អត់មានក្តាមមឈូសទេមានតែរនៀបឫស្សីយើងនិង មិនទាំងផុតដៃផុតជើងផង គេត្រងរនៀបនិងរើទៅនិងគេយើឈ្នួលយើងម្នាក់មួយកំប៉ុង អង្ករសម្រួបនិងមីងកិនងោយគេទៅអង្ករបានបួនកំប៉ុង សល់ប៉ុន្មានសល់ប្រហែកមួយកំប៉ុងចឹងទុកបបរហូបខ្លួនឯង ហើយគេបួននាក់គេយកម្នាក់មួយកំប៉ុនៗនិង ហើយមីងអោយគេទៅអង្ករសម្រួបនីងសល់មយយកំប៉ុងទុកបបរហូបខ្លួនឯង ដាក់ម្តងមួយក្តាប់ទៅៗហើយរកត្រកួនមកយកមកដាក់លាយទៅ៕

ក៖ ឪពុករបស់អ្នកមីងគាត់មានឈ្មោះអ្វីដែរ?

ខ៖ ប៉ាត់ យើន

ក៖ គាត់មានអាយុប៉ុន្មានដែរហើយអ្នកមីង?

ខ៖ ប្រហែលជាជំនាន់នុងគាត់ចូលហុកសិបជាងហើយ ជំនាន់នុងគាត់ចូលហុកហើយ៕

ក៖ អ្នកមីងអាចដឹងពិឆ្នាំកំនើតរបស់គាត់ដែរទេ?

ខ៖ មីងអត់ដឹងអត់ស្គាល់ផង មីងអត់ថាឆ្នាំអីខែអីទេ អត់ដឹងទេ គាត់អត់និយាយណាគាត់អត់និយាយប្រាប់ណា ទោះបីឆ្នាំម្ដាយក៏ងត់ដឹងថាគាត់ឆ្នាំអីដែរ៕

ក៖ អ្នកមីងតើអាចដឹងថាទីកន្លែងកំណើតរបស់ឪពុកអ្នកមីងនៅភូមិឃុំអ្វីដែរទេ?

ខ៖ នៅនិង នៅស្រុកកំណើតនៅនិងតែម្ដង៕

ក៖ គេហៅភូមិឃុំអ្វីដែរអ្នកមីង?

ខ៖ និងភូមិរនេះ ស្រុកកោះដាច់ ខេត្តកណ្ដាល ពីមុនស្រុកមុខកំពូល ប៉ុន្តែឥឡូវគេប្ដូរហើយ ភូមិកោះដាច់ ខណ្ឌជ្រោយចង្វា រាជធានីភ្នំពេញ វិញនិងហើយ៕

ក៖ ចុះចំណែកឯម្ដាយរបស់អ្នកមីងវិញគាត់មានឈ្មោះអ្វីដែរ?

ខ៖ ម្ដាយខ្ញុំឈ្មោះអើរ ឡុង បិត និងហើយប៉ុន្តែស្រុកគាត់និងគេហៅតែ យ៉ាន់ៗទេនិងហើយស្រុកគាត់និង ស្រុកគាំត់និងនៅឯស្រុកស្រែ៕

ក៖ ទីកន្លែងកំណើតគាត់នៅភូមិឃុំអ្វីដែរ?

ខ៖ នៅភូមិត្រពាំងវែងឯនុងខេត្តកំពង់ស្ពឺហាណានាង និងហើយខេត្តកំពង់ស្ពឺ គាត់នៅស្រុកគាត់និងគេហៅបិតៗដល់មកនៅស្រុកនេះគេហៅតែយ៉ាន់ៗទេ៕

ក៖ គាត់មានអាយុប៉ុន្មានដែរ នៅពេលដែរគាត់មានជីវិតអ្នកមីង?

ខ៖ ប្រហែលជាហាជាងហើយចូលហាប្រាំអីហើយ កាលជំនាន់នុងថាប៉ុននិងចុះ៕

ក៖ អ្នកមីង តើអ្នកមីងធាចដឹងពីឆ្នាំកំណើតគាត់ដែរទេ?

ខ៖ អត់ដឹងផង សុទ្ធតែងត់ដឹងឆ្នាំកំណើតរបស់ឪពុកម្ដាយទាំងអស់៕

ក៖ អ្នកមីងអាចដឹងដែរទេថា ហេតុអ្វីបានជាម្ដាយរបស់អ្នកមីងគាត់ស្លាប់?

ខ៖ គាត់ស្លាប់និងដោយសារគាត់ខូចចិត្តនិងប្ដីគាត់ស្លាប់ ខូចចិត្តនឹងប្ដីផង ហើយថៅនិងនិយាយទៅត្រូវជាថៅតែហៅ គាត់ថាម៉ែៗណាខឹងចិត្តនឹងស្លាប់ផង ស្លាប់និងយើងពីដើមអាស្រាសាច់ដុំយើងពីដើមនិង គេដាក់លាយជាមួយថ្នាំអីទេអានិងជាដថ្នាំរាក ដល់ពេលថ្នាំរាកនិងគេអោយគាត់តែមួយថ្ងៃនិងមួយស្លាបព្រាការហ្មេទេ គាត់មិនមែនតែមួយស្លាបព្រាការហ្មេណា អាកែវទន់ៗយើងពីដើមនិងអាកែវចរណៃគេហៅកែវចរណៃនិង មួយនិងកន្លះលីត្រណា ហើយគាត់ដាក់ម្ដងមួយអានិង វាទៅជាប្រតិកម្មថ្នាំនិងវាទៅជាខោចមាត់ខោចអីអស់រលីង ហើយតានិង

សួរថាហើយមីនាងឯងថី ម៉ែខ្ញុំគាត់ប្រតិកម្មថ្នាំតាអើយ ចឹងមីនាងឯងរត់យកដើមត្របែកទៅ រត់ពីរនាក់បងប្អូននិងយកមក យកមកដាក់អាំងនិង ដាំទឹកប្រជកអោយគាត់និងទម្រាំតែបានចូលនិងញីផង កោសស្លាបព្រាទៀតណា យកស្លាប់ព្រានិងកោសអោយគាត់ហានិងប្រជកទៅបានធូមកវិញ បានគាត់និយាយកើតនិងហើយខ្ញុំថាម៉ាក់ឯងឈប

ពិសាទៅហើយខ្ញុំយកទឹកនិងទៅបោះចោលទៅ អាទឹកថ្នាំនិងហើយសួរថាម៉េចបានម៉ាក់ឯងពិសារអាទឹកនិង ចឹងម៉ាក់ឯងអត់ចេះអាណិតកូនទេហ៎បើពុកស្លាប់ហើយ ម៉ាក់ឯងទុកអោយកូននិងជាមួយអ្នកណា ហើយថាម៉ាក់ទៅនៅជាមួយពុកកូនឯងហើយ តិចទៀតពុកកូនឯងមកយកម៉ែទៅហើយ រួចបើម៉ែឯងទៅចឹងអត់អាណិតកូនទេចឹង ហ៏មម៉ែជាមួយពុកកូនឯងហើយ បានប៉ុន្មានថ្ងៃដែរគាត់និយាយប្រាប់មីងនិងប៉ុន្មានថ្ងៃប្រហែលជាពីរថ្ងៃគាត់ស្លាប់និងគាត់រាកនិងហើយគាត់ស្លាប់ទៅមុននឹងគាត់ស្លាប់និងគាត់ចេះតែរមាស់ចៃនិងចេញមកពេញមុខពេញមាត់និងគាត់ ហើយមីងអត់មានអីកោរមានតែកាំបិតតាំងតោនិងសំលៀងទៅពីរនាក់បងប្អូននិងកោរអោយម្ដាយទៅ កោរទៅស្អាតមិនស្អាតចេះតែកោរទៅយកទៅដាក់និងគោលដូងទៅហើយថ្ងៃចេញមកថាឡើងខ្មៅងងឹតសុទ្ធតែចៃ គ្រាន់តែក្រឡែកមើលទៅអស់ចៃឡើងអស់រលីង មិនដឹងទៅណាអត់ឃើញបានតែប៉ុន្មានថ្ងៃ ប្រហែលជាបីបួនថ្ងៃគាត់ស្លាប់ទៅ៕

ក៖ នៅពេលដែរគាត់នៅមានជីវិតនិង គាត់ធ្វើអ្វីដើម្បីចិញ្ចឹមដែរអ្នកមីង?

ខ៖ គាត់និងគេអោយនៅមើលក្មេងៗ ដូចថាម្ដាយគេទៅធ្វើការចឹងណា គេអោយមើលកូនអោយគេនិងហើយទៅគេអោយអង្ករ ម្នាក់និងគេអោយមួយកំប៉ុងអីចឹងទៅនិងគេអ្នកមានណាមួយកំប៉ុងឯកន្លះកំប៉ុងអីចឹងទៅគេអោយគាត់និង ហើយគ្រាន់បានចិញ្ចឹមកូននិង ប៉ុន្តែគ្មានទេជំនាន់និងគរមិនអោយយើងដាំបាយខ្លួនឯងផង គេមិនអោយឃើញផ្សែងផងនិងបើដាំបានបានតែយប់ទេ យប់ស្ងាត់និងយើងអាចដាំហូបបានបើថាថ្ងៃយើងអត់បានដាំហូបបានទេព្រោះថា កាលនុងយើងហូបរួមយើងមិនអាចដាំហូបឯកជនបានទេ បើដាំទៅទល់តែម៉ោងដប់ពីរយប់អីណ៎អានិងបានដាំហូបបានទល់តែគេដេកលក់ស្ងាត់អស់ហ៎ យើងអាចដាំបានតែបើដាំនិងមិនអាចដាំឆ្នាំងបានទៀត ព្រោះឆ្នាំងនិងអត់មានទេគេសែកយកអស់ហើយមានតែ កំសៀវទឹកមួយនិងមីងដាំនិងកំសៀវទឹកនិងទៅ ដាំកំសៀវទឹកចឹងទៅគេដឹងថាយើងដាំទឹកហើយអត់ដឹងថាយើងនិងដាំបាយទេ គេអត់ដឹងទេគេអត់ដឹងថាយើងមានអង្ករដាំបាយទេ យើងដាំនៅកំសៀវនិងទៅហើយដល់ពុះចឹងទៅយើងជួតម្ដងចឹងទៅបើយើងអត់មានអង្ករអីច្រើន យើងបបរចឹងទៅតែបើមានអង្ករច្រើនចឹងទៅយើងដាំបាយចឹងទៅ អោយមានកម្លាំងចឹងទៅបើសិនមានអង្ករតិចយើងបបរចឹងទៅ ក្នុងមួយកំប៉ុងនិងយើងលៃម៉េចអោយបានពីរទៅបីថ្ងៃអីចឹងទៅ អោយមានជាតិអង្ករ

ច្រើនដាក់មួយក្ដាប់ពីរក្ដាប់អីចឹងទៅបបរនោះ មិនហ៊ានដាក់ច្រើនទេដាក់ច្រើនទៅយើងខ្លាចអស់យើងហូបតែមួយពេលៗទេ ខ្លាចអស់យើងទុកថ្ងៃក្រោយទៀតទៅណាំយើងសន្សំសំចៃ៕

កៈ ឪពុកម្ដាយរបស់អ្នកមីង គាត់កើតនៅក្នុងសម័យប៉ុលពតឬក៏មុនសម័យប៉ុលពតដែរអ្នកមីង?

ខៈ ជំនាន់ប៉ុលពត ចាសជំនាន់ប៉ុលពតនិងតែម្ដង អត់មានក្រោតតែមុនក្នុងសម័យប៉ុលពតនិងតែម្ដងនិង៕

កៈ ចឹងបានន័យថានៅសម័យប៉ុលពតនិង អ្នកមីងអត់បានរស់នៅឆ្ងាយពីឪពុកម្ដាយទេ?

ខៈ ចាស អត់ទេដូចជារស់នៅជាមួយបែកតែបងៗទេ និងហើយបែកតែបងៗទេមួយទៅចល័តមួយទៅសមរភូមិអីចឹងទៅណា ស្រេចតែបញ្ជូនទៅៗហើយយើងនៅតូចគេអោយនៅផ្ទះនៅតាមកងចឹងទៅ រួចមកពីរៀនវិញទៅរែកដីចឹងទៅម៉ោងប្រាំពីរព្រឹកមកវិញមក ម៉ោងបីទៅទៀតទៅសាងសង់សាលារៀននិងរែកដីចឹងទៅហើយម៉ោងប្រាំពីរព្រឹកចឹងទៅមកវិញមក ដឹងតែម៉ោងបីៗទៅហើយដល់ម៉ោងប្រាំពីរព្រឹកដឹងតែមកវិញហើយ រៀនក៏មិនសូវបានប៉ុន្មានដែរនាងអើយរៀន អត់ពីឪពុកម្ដាយទៅអក្សរអីនិងរត់ទៅគ្រូវិញអស់ហើយចឹងបានថាស្ដាយ រៀនជំនាន់នុងចូលរៀនបានមួយថ្ងៃមកវិញងត់បាយស៊ីឈប់ទៅរៀនរហូតទៅ ដើរបេះផ្លែឈើអីផ្លែស្រដាន់អីនិងយកទៅហាលទៅកាលនុងជំនាន់៧៩ និងហានាងអើយមិនបានរៀនសូត្រនិងគេចឹងបានថាពិបាក៕

កៈ អ្នកមីងមានបងប្អូនបង្កើតចំនួនប៉ុន្មាននាក់ដែរ?

ខៈ មានប្រាំបីនាក់៕

កៈ អ្នកមីងជាកូនទីប៉ុន្មានក្នុងគ្រួសារដែរ?

ខៈ កូន៣៕

កៈ បងៗរបស់អ្នកមីងគាត់មានឈ្មោះអ្វីដែរ?

ខៈ យើនយើន យើនយ៉ាន យើនយៃ៉ យើនសុខន យើនយឿន យើនយ៉ន់៕

កៈ សព្វថ្ងៃបងៗរបស់អ្នកមីងពួកគាត់ធ្វើអ្វីដែរ ហើយរស់នៅណោដែរ?

ខៈ នៅជាមួយគ្នានិង នៅស្រុកនិងគេត្បាញ ធ្វើត្បាញធ្វើអីនិងនៅជុំគ្នាហៃរហងនិង ធ្វើត្បាញនិងធ្វើសឹងនិង៕

ក៖ មូលហេតុអីបានជា អ្នកមីងបានរស់នៅជាមួយបងប្អូនក្រោយពីបែកសម័យប៉ុលពតវិញ??

ខ៖ មុនបែកគ្នាតែនៅពេលដែរយើងចង់មកស្រុកចឹង ចឹងទៅបែកគ្នាអស់ហើយណាដល់យល ងចង់មកស្រុកចឹងយើងមកជាមួយបងជីដូនមួយ មកជាមួយបងជីដូនមួយនិងមកតាមផ្លូវនិងម កហើយគេទៅស្រុកគេនិងទៅស្រុកគេនៅឯលើហ៎ ស្អីទេគេហៅស្រុកខ្វងអីគេនិងគេទៅនៅឯ នៅ ទៅឯនុងបានប្រាំថ្ងៃគាត់ត្រឡប់មកវិញត្រឡប់មកស្រុកយើងវិញ មកវិញនិងដើរមកដើរ តាមស្រែខាងកើតនិង ដើរមករហូតមកបានមកដល់មកឆ្លងដរនៅពុកឫស្សីនិងបានមកជួបជុំ គ្នានៅឯស្រុកនិង៕

ក៖ ចឹងហើយបានរស់នៅជាមួយនិងគ្មាន?

ខ៖ និងហើយ!

ក៖ ចុះចំណែកឯអ្នកមីងវិញ អ្នកមីងមានឈ្មោះអ្វីដែរ?

ខ៖ យើន ស្រីម៉ៅ៕

ក៖ កាលពីតូចមកអ្នកមងមានឈ្មោះហៅក្រៅពីនិងដែរទេ?

ខ៖ មានតែឈ្មោះនិង មានតែប៉ុន្តែអត់ហៅ និងហើយ៕

ក៖ ពីមុនមានឈ្មោះអ្វីដែរអ្នកមីង?

ខ៖ អើរឈ្មោះ
ពីមុនដាក់តាមជីតាឯនោះ ហៅឡុង ស៊ីដេត ប៉ុន្តែហៅតែឈ្មោះនោះមួយ ឈឺច្រើនពេកឈប់ ហៅអត់ហៅទៅ ហៅតែឈ្មោះនិង ព្រោះពីក្មេងនិងឈឺច្រើន៕

ក៖ សព្វថ្ងៃអ្នកមីងមានអាយុប៉ុន្មានដែរហើយ?

ខ៖ ប្រហែលជាហាសិបប្រាំហើយ៕

ក៖ ចឹង អ្នកមីងកើតនៅក្នុងឈ្នាំណាដែរ?

ខ៖ អត់ស្គាល់ឆ្នាំទាំងអស់ ៕

ក៖ ចុះឆ្នាំខ្មែរយើងទាំងដប់ពីរ តើអ្នកមីអកើយនៅក្នុងឆ្នាំមួយណា?

ខ៖ នៅក្នុងឆ្នាំណាទេនាងអើយ ទល់តែម្តាយយើងបានគាត់ចាំដែរនិងណា!

កៈ នៅក្នុង ខាល ថោះ រោង ម្យាញ់អីណាអ្នកមីង?

ខៈ ដឹងតែថាឆ្នាំម្សាញ់ និងហើយដឹងតែឆ្នាំនិង ប៉ុន្តែខែមិនដឹងទេណា និងហើយអត់ដឹងថាខែអីទេ៕

កៈ ចុះទីកន្លែងកំណើតរបស់អ្នកមីង នៅភូមិឃុំអ្វីដែរ?

ខៈ នៅឃុំនិង ភូមិរនេះ សង្កាត់កោះដាច់ ខណ្ឌជ្រោយចង្វា និង៕

កៈ កាលពីអ្នកមីងនៅក្មេងវិញ តើអ្នកមីងចូលចិត្តលេងឬក៏ធ្វើអ្វីខ្លះជាមួយនឹងបងៗរបស់អ្នកមីង?

ខៈ អត់មានបានធ្វើអីផង៕

កៈ តើអ្នកមីងនៅចាំឈ្មោះជីដូនជីតាខាងម្ដាយរបស់អ្នកមីងដែរទេ?

ខៈ នៅចាំតែនៅចាំតែជីតាទេ ជីតាឈ្មោះឡុង តែបើយាយមិនដឹងជាឈ្មោះអីទេ អត់ចាំទេ ឈ្មោះជីតានិងចាំតែឈ្មោះយាយនិងអត់ចាំទេ៕

កៈ តើអ្នកមីងអាចដឹងពីទីកន្លែងកំណើតរបស់លោងតាដែរទេ?

ខៈ គាត់នៅស្រុកនិងតែម្ដង ហើយតាខាងម្ដាយនិងក៏គាត់នៅស្រុកត្រពាំងវែងនិងដែរ៕

កៈ លោកតា អំបិញមិញនេះជាលោកតានៅខាងឪពុកឬក៏ខាងម្ដាយ?

ខៈ ខាងឪពុកនិងឈ្មោះតាប៉ាត់ ខាងម្ដាយនិងឈ្មោះឡុង និងហើយប៉ុន្តែគ្រាន់តែមិនស្គាល់ឈ្មោះប្រពន្ធឈ្មោះអី វែខាងនេះកជអត់ស្គាល់ដែរតែយាយនិងក៏មិនដឹងឈ្មោះអីដែរ៕

កៈ តើអ្នកមីងអាចដឹងពីអាយុរបស់លោងតាដែរទេ?

ខៈ អត់ចាំទេ ព្រោះកើតអត់ទាន់និងហើយ កើតអត់ទាន់តាបើបងៗនិងគេទាន់ខ្ញុំអត់ទាន់ទេ៕

កៈ ចឹងបានន័យថា ក្រុមគ្រួសាររបស់អ្នកមីងរស់នៅភូមិរនេះ សង្កាត់ជ្រោយចង្វា រាជធានីភ្នំពេញនេះអស់រយះពេលយូរហើយ?

ខៈ យូរហើយតាំងពីយើងចប់ និយាយទៅតាំងពីសង្គមនិងមក បើចប់អាពតមកក៏នៅនិងអត់មានទៅណាទៀតនៅតែនិង៕

កៈ តើអ្នកមីងមានបងប្អូនឬក៏សាច់ញាតិដែររស់នឹងក្រៅប្រទេសដែរទេ?

ខ៖ មានមួយដែរ ប៉ុន្តែគាត់នៅឯនុងក៏ខ្យត់ខ្សោយដែរ មិនសូវជាមានណាស់ណាដែរទេ ដើរតែស៊ីឈ្នួលបេះផ្លែឈើអោយគេនិង ម្លោះហើយបានជាគាត់មិនសូវមានលុយផ្ញើរមកដែរ បានផ្ញើរមកអោយធ្វើតែបុណ្យគាត់បោះហោះអោយមើលដែរ ដើរបេះអាផ្លែស្រ្តប៊េរីនិងតាមរង ជូនណាទៅលុតជង្គង់បេះក៏បានដែរជំបៅរលះរលួយអស់ហើយគាត់បោះហោះអោយមើលនិងណា ហើយថាហឹម ដូចតែខ្ញុំដែរដើរស៊ីឈ្នួលដើរបេះដេះត្រសក់អោយគេដែរនិង ថាអើរដូចតែគ្នានិង៕

កៈ បងអ្នកមីងគាត់នៅប្រទេសណាដែរ?

ខ៖ គាត់នៅឯសហរដ្ឋអាមេរិក

កៈ តើគាត់មានឈ្មោះអ្វីដែរអ្នកមីង?

ខ៖ គាត់ឈ្មោះ យើន សំអាត គាត់ផ្លាស់ឈ្មោះណាំ យើនសំអាត ពិមុនដាក់នាមត្រកូលជីតា ដល់មកពេលឥឡូវនេះគេអត់ដាក់ជីតាទេ ព្រោះដាក់ជីតាគេក្រោយអ្នកអត់ស្គាល់តាយើងគេពិបាករក តែបើសិនជាចាស់ៗយើងជំនាន់មុន គេស្គាល់និងឯត់អីទេគេមករកយើង ដល់ទៅពេលឥឡូវគេអោយដាក់នាមត្រកូលឪពុកវិញ ហើយចឹងបានជាមីងដាក់នាមត្រកូលឪពុករហូតមកនិង យើនស្រីម៉ៅនិង ហើយទៅអ្នកណាស្គាំល់គ្នាចឹងទៅគេចង់មករកចឹងទៅគេស្គាល់ចឹងទៅគេថាអ៎ផ្ទញនៅឯនេះនៅឯនោះចឹងទៅ បើដាក់ឈ្មោះជីតាគេអត់ស្គាល់ទេ មិនដឹងជានិយាយទៅគេអត់ស្គាល់តែម្តង បើដាក់ឈ្មោះឪពុកនិងបានគេងាយស្រួលរកយើងឃើញ ចឹងបានមីងដាក់នាមត្រកូលឪពុកមករហូតចឹងទៅ ៕

កៈ ទាក់ទងនឹងចំណងអាពាហ៍ពិពាហ៍របស់អ្នកមីងវិញ ស្វាមីអ្នកមីងគាត់មានឈ្មោះអ្វីដែរ??

ខ៖ អត់មានផង មីងអត់មានទេ៕

កៈ កូនក៏អត់ដែរ៕

ខ៖ ចាស អត់យកប្តី មើកទៅដូចបីបាកណាស់ក្មួយអើយគេចង់បានដែរតែមើលទៅយកមកមិនដឹងផ្លូវលើកទុកលើកអីដូចថានាងឯងចុះទៅរកនៅឯណាទៅរកទៅ មីងមិនយក៕

កៈ មូលហេតុអ្វីបានជាអ្នកមីង អត់យកស្វាមីចឹង?

ខ៖ មិនដឹងជា យ៉ាងម៉េចមិនយកតែម្តង ដូចឃើញស្អប់តែម្តងមិនចូលចិត្តចាស ដូចមិនចូលចិត្តតែម្តង ដូចថាគេចង់បានបីបួននាក់ដែរតែមិនយក មកទៅមកទៅសុទ្ធមកផ្លូវដូចមិនប្រកបសុ

ទូតែមកផ្លូវមួយតែម្នាក់ឯងចឹងណា អ្នកដើរមកនិងមិនដឹងផ្លូវយកទៅទុកនៅឯណាចឹងទៅណា មិនយកទេដាច់ខាត៕

ក៖ ចឹងសព្វថ្ងៃអ្នកមីងរស់នៅជាមួយនឹងអ្នកំាគេដែរ?

ខ៖ នៅម្នាក់ឯង ចាសផ្ទះនិងក៏ផ្ទះគេដែរ សុំផ្ទះគេនៅអត់មានផ្ទះអត់មានសំបែងទេ គ្រាន់តែមកសុំជ្រកកោនរហូតដល់យើងអស់ជីវិតចឹងទៅ៕

ក៖ ចុះចំណែកឯបងៗរបស់អ្នកមីង អ្នកមីងមិនទៅនៅជាមួយនិងបងៗរបស់អ្នកមីងទៅ??

ខ៖ និងនិយាយទៅវាពិបាកណាស់នាងអើយ រឿងគ្រួសារយើងពិបាកយើងអត់យើងនៅជាមួយគេយើងពិបាករស់នៅណាស់ យើងខ្សត់ខ្សោយដល់គេវាមានចឹងបានមីងដើររស់នៅ យើងនៅតែយើងទៅគេនៅតែគេទៅ៕

ក៖ ចុះអ្នកមីងកាលពីក្មេងភាសារខ្មែរយើង តើអ្នកមីងចេះអានចេះសរសេរបានល្អដែរទេ?

ខ៖ មើលទើបតែមីងមករៀនថ្នាក់អក្ខរកម្មប៉ុន្មានឆ្នាំនិងមក បានមីងរៀងចេះបានមើលខ្លះៗដូចថាជួនណាអក្សរស្រួលអានចឹងទៅយើងចេះមើលចេះអានបានខ្លះៗតែបើអក្សររៀងពិបាកជាងនិងយើងអត់អានណា អត់បានរៀនទេនាងអើយចឹងបានថានឹកឃើញស្តាយក្រោយកាលពីជំនាន់យើង៧៩និងទោរៀបបានមួយថ្ងៃនិង មកដល់ផ្ទះបើឆ្នាំងមើលឃើញអត់បាយហូបនិងមីងឈប់ទៅរៀនរហូត អោយតែក្មួយមួយនិងទៅរៀននិង ចឹងបានថាគេទៅរៀនថ្នាក់អក្ខរកម្មនិងមីងទៅរៀននឹងគេនិងទៅ និងបើសិនជាគេចូលរៀនទៀតមីងទៅរៀនថ្នាក់អក្ខរកម្មចាស់ៗណាទៅរៀនដែរតែបានតែមួយខែអីនិងឈប់បង្រៀននិងមិនសូវចេះអក្សរ៕

ក៖ ចុះចំណែកឯភាសារដែរ ក្រៅពីភាសារខ្មែរយើងតើអ្នកមីងចេះភាសារអីក្រៅនិងដែរទេ?

ខ៖ អត់ៗចេះតែម្តង ចឹងបានថារាល់ថ្ងៃនិងអោយតែគេមក ថាបង្រៀនថ្នាក់អក្ខរកម្មនិងរៀន ចង់ចេះណាស់នាងអើយ ចង់ចេះតែបានមើលសៀវភៅធម៌ដាច់និងចេះយកអរគុណពេក ចឹងបាននឹកឃើញថាស្តាយក្រោយបើរៀនតែជំនាន់នុងត្រឹមថ្នាក់ទៅ៦ឈប់នឹងក៏យើងបានចេះយកអក្សរច្រើន ប៉ុន្តែបើមកដល់ផ្ទះបើឆ្នាំងជំនាន់នុង៦៩នុងនាងអើយអត់អង្ករហូបជួនណាអង្ករយើងពោតសំលីណា ស្រូវពោតសាលីនិងគេហាលន់ទៅបើកដល់កោះដាច់ណំ ទៅបើកមកទៅមួយគ្រួសារបានមក៣គីឡូរអៅចឹងទៅ លាយជាមួយអាអង្ករយើងកន្លះកំប៉ុងទៅលាយជាមួយអង្ករនិងមួយកំប៉ុងអីចឹង ហើយជួនណាទៅអាគ្រប់ប្រលិតយើងនិង អាគ្រប់ប្រលិតយើងស្លនិងផ្លែវាអាទំៗនិងយកមកប្រលះវាចឹងទៅយកទៅដាក់ត្រាំទឹកចឹងទៅដោយវារីក ហើយលាងអោ

យស្អាត់អារាំអិលវានិងហើយយកមកដាក់ហាលថ្ងៃ ហើយយកមកលីងធ្វើជាអង្គរមួយកំប៉ុងចឹង ទៅអង្គរយើងកន្លះកំប៉ុងចឹងទៅយកមកដាក់លាយ កាលជំនាន់នុងអត់ណាកាល៦៩យើងរក អីអត់បាន យើងមិនដឹងទៅរកអីនៅឯណា ដល់ពេលបានមកផុតនេះជំនាន់នុងប្រហែលជាចូ ល៨០អីចឹងទៅដើរបេះស្រដាន់អីចឹងទៅយកទៅលក់ទៅ ធ្វើនំបញ្ចុកធ្វើអីយកទៅលក់ចឹងទៅ ទូលទៅដល់គីឡូលេខ៦លេខ៧អីចឹងអ៎ ជួនណាដាច់ចឹងទៅជួនណាចេះតែសល់ដើរលក់ទៀ តចឹងទៅ មកផ្សារចាស់ផ្សារថ្មីអីចឹងទៅជំនាន់នុងអត់ទាន់មានផ្ទះច្រើនដូចឥឡូវទេ កាលជំនា ន់នុងតាមជ្រោយចង្វារតាមធីនិងចជតែដើរជ្រៀតចូលចឹងទៅ
ដល់ពេលឈប់ធ្វើនំបញ្ចុកចឹងទៅមកធ្វើត្បាញ ត្បាញមករហូតចឹងទៅយើងស្រួលដែរ៕

ក៖
អ្នកមីងក្រៅពីការត្បាញ ការលក់នំបញ្ចុកអីចឹង តើអ្នកមីងមានបានធ្លាប់ដលរទៅស៊ីឈ្នួលគេ ទៀតដែរទេ?

ខ៖ ដើរបេះត្រសក់អោយគេរាល់ថ្ងៃបានមកដល់ខែទឹកលិចនិងទោ បានអត់បានទៅៗបេះតែ ព្រឹកៗទេបើគេរកបេះល្ងាចចឹងទៅ នោនុងមួយថ្ងៃរល់ល្ងាចចឹងទៅជួនណាទៅគេអោយយើង នៅហូបបាយទៅ ចឹងទៅយើងមិនបាច់ចាំមកយើងនៅទល់ល្ងាចចឹងទៅ និងបេះអស់ផ្លែចឹង ទៅវាអស់ត្រសក់បេះនៅផ្ទះត្បាញចឹងទៅ តែបើសិនជាគេមានទៅៗតែកុំតែទឹកលិចកុំអីនៅនិ ងព្រៃទៀតនិងទៅបេះត្រសក់អោយគេទៅ៕

ក៖ ស៊ីឈ្នួលបេះត្រសក់ដោយគេនិង បានថ្លៃចំនួនប៉ុន្មានដែរទៅ?

ខ៖ គេអោយមួយព្រឹកនិង២០០០០តែជួនណាដាំទៅមួយល្ងាចនិងគេអោយ១៥០០០តែបើយើ ងដាំពេញមួយថ្ងៃចឹងទៅយើងអត់ទាន់មានផ្លែបេះចឹងទៅណា យើងដាំនិងពេញមួយថ្ងៃបាន៣ ០០០០មួយថ្ងៃ៕

ក៖ កាលពីអ្នកមីងនៅក្មេងនិង អ្នកមីងបានរៀនត្រឹមថ្នាក់ទីប៉ុន្មានដែរទៅ?

ខ៖ អត់បានរៀនទាំងអស់ និងហើយដូចក្មេងខ្លាចសាលាណា យើងក្មេងខ្លាចសាលានោះខ្លាច សាលាហើយខ្មាក់គេទៀតមនុស្សច្រើនចឹងបាននៅតែផ្ទះ គេហៅទៅចម្លងដរទៅទៅចម្លងដរ ទៅចារទៅពីនាក់ឪពុកនិងជួនណាទៅរៀនចារតែម្នាក់ឯង ពីនាក់បងចឹងទៅ៕

ក៖ ជីវិតរបស់អ្នកមីងមានការផ្លាស់ប្តូរអ្វីខ្លះដែរទេ តាំងពីតូចរហូតមកដល់ពេលឥឡូវនេះ?

ខ៖ ផ្លាស់ច្រើននាងអើយ ប៉ុន្តែគ្រាន់តែយើងរកស៊ីចិញ្ចឹមខ្លួនឯងតាំងពីអាយុ១៣ឬ១៤ឆ្នាំយើងរកមករហូតតាំងពីបែកជំនាន់ប៉ុលពតនិងមក មនុស្សចំណាស់និងហើយមិនអាចពឹងផ្អែកគេបានណាមនុស្សយើងនៅជាមួយគេ ទល់តែយើងធ្វើការអោយគេបានគេដោយបាយយើងហូបត្បិតតែបងប្អូនបង្កើតមែន បើសិនជាអត់ទេគេហូបនៅសល់បាយចឹងគេជះចោលគេអត់អោយយើងហូបទេ ចឹងបានមីងថាពិបាកហើយអត់នៅជាមួយគេសុខចិត្តរកស៊ីខ្លួនឯងរហូតឈប់នៅជាមួយគេ អត់មានថានៅជាមួយនិងគេទេនៅតែជាមួយនិងបងប្អូនឯងនិងប៉ុន្តែចិត្តវាអត់បានណា យើងខំស្រលាញ់គេប៉ុន្តែគេអត់ស្រលាញ់យើង៕

ក៖ ទាក់តងទៅនិងចំណង់ចំណូលចិត្តរបស់អ្នកមីងវិញ

តើអ្នកមីងចូលចិត្តបរិភោគអាហារអ្វីដែរ?

ខ៖ ពីក្មេងមីងចូលហូបបាយតែវាមួយនិងទឹកស៊ីអៀវទេ មានត្រីព្រោះផ្ទះគ្រួសារមីងនិងឪពុកអ្នកវាយមង វាយមងទនេរយើងនិងពីដើមសំប្បូរត្រីណាស់ ត្រីផ្តួលអីនិងផ្ទះមីងហូបទល់តែដល់ខែវិញត្រី ដល់ទៅពេលស្លាក់ឆ្អឹងត្រីផ្តួលនិងឪពុកមីងគាត់លូកដោយឈាមតាំងដុំមកនិង មីងឈប់ហូបត្រីរហូតទល់តែជំនាន់អាពតនិងគេអោយហូបអត់ហូបតែខ្លាចស្លាក់ឆ្អឹង ហើយម្តាយមីងនិងគាត់ទៅទិញសាច់ជ្រូកកន្លះគីឡូរអីចឹងមកឬមួយគីឡូរចឹងទោគាំត់យកមកគាត់ប្រឡាក់អោយ ទុកអោយហូបចឹងទៅដល់ទៅពេលអត់គាត់អត់លុយដែរចឹងទៅជាមួយនិងទឹកស៊ីអៀវនិងហើយអត់ទេ ដល់ទៅពេលមានត្រីចឹងទៅម្តាយមីងនិង អង្គុយបេះទុកមួយចាននិងអោយស្អាតចឹងទៅ ដល់ពេលឃើញត្រីនិងទៅយំលេងស៊ីហើយអត់ទេម៉ែខ្លាចស្លាក់ឆ្អឹងទៀត អត់អីទេម៉ែបេះអោយហើយៗធំហើយនិងណាំមិនមែននៅក្មេងទៀតណា ធំហើយប្រហែលជាអាយុ៩ឆ្នាំ១០ឆ្នាំអីនិងណា ម៉ែអត់ទេកូនខ្លាចស្លាក់ឆ្អឹងតៀតអត់អីតេកូនម៉ែបេះអស់ហើយ អត់ទេម៉ែនៅតែអត់និងអោយទឹកស៊ីអៀវមកហុបតែទឹកស៊ីអៀវនិងទៅ ហើយម៉ែនិងគាត់ដាក់តែទឹកស៊ីអៀវអោយមកហូបតែទឹកស៊ីអៀវនិងទៅដើរទៅលេងផ្ទះម្តាយមីងនិងបាត់ទៅចឹងទៅ៕

ក៖ ចុះចំណែកឯការច្រៀងការរាំ ការស្តាប់បទចំរៀងអីចឹង តើអ្នកមីងចូលចិត្តដែរទេ?

ខ៖ ចូលចិត្តដែរតែដល់មកពេលចាស់ទៅលេងហ៊ាន តែមិនសូវាបានលេងទេនាងអើយបានទៅតែមើលគេនិង យើងជាប់មើលក្មួយនិងយើងមើលកូនអោយតែគេនិង គេដើរទៅបាត់ទៅយើងមើលកូនអោយតែគេចឹងទៅ បើថាល្ខោនអីនិងចូលចិត្តណាស់ល្ខោន៕

ក៖ នៅក្នុងគ្រួសាររបស់អ្នកមីង តើមានសមាជិកណាដែរគាត់ចេះលេងឧបករណ៍ភ្លេងខ្មែរដែរទេ?

ខ៖ អត់មាន មានដែរមានបងប្រុសមួយបង្អស់និងខាងចំរៀងគាត់ទៅប្រលងខាងចំរៀង មានតែបងមួយនិងមួយបងប្អូនទាំងអស់មានតែគាត់ទេរៀនបានខ្ពស់ជាងគេ ភាសាអិក៏គាត់ចេះដែរ ហើយនិងគាត់ទៅប្រលងចំរៀងជាប់ហើយគេមានឈ្មោះនិងដែរ គេមានឈ្មោះស្រដែងយើងដែរប៉ុន្មានមាននាមត្រកូលខុសគ្នានិងគេប្រលងធ្លាក់និងគេយកឈ្មោះយើងនិងទៅ៕

ក៖ សព្វថ្ងៃគាត់រស់នៅទៅណាដែរអ្នកមីង?

ខ៖ បែកតាំងពីយើងនិងមក រហូតមកនាងអើយមើលកាលពីជំនាន់នុងគាត់៧៩និងគាត់ចូលមកស្រុកដែរដល់ចូលមកគាត់សួរមិត្តភក្តិគាត់និងថាឯងទៅមើលៗ ប្រហែលបងប្អូនមកនៅស្រុកនិងហើយគាត់ថាអត់ទៅទេ គាត់ថាអ្នកដែរទៅស្រុកបាត់ដំបងនិងច្រើនតែទៅដប់គ្រួសារអីនៅសល់តែពីឬគ្រួសារអីចឹងទៅណា ហើយចឹងគាត់ថាសុខចិត្តនារទេះខ្លួនចេញពីស្រុករហូតមកដល់តឡូវនិងទៅ មីងមកតាមនុងដែរតែជ្រោះគ្នាបានមួយថ្ងៃចូលមកជាមួយគ្នាប៉ុន្តែភ្លៀងពេកជំនាន់នុងទឹកឡើងចឹងទៀតណា ទឹកឡើងហើយទៅយំសួគេមានឃើញបងខ្ញុំទេ គេរថាវាឆ្លងទៅវិញហើយវាថាម៉ែឪងាប់អស់ហើយទាំងហែងទាំងអីនិងគេងោយមកសួរដែរ វាអត់មកឆ្លងទៅវិញតាមបុកឫស្សីនិងទៅហើយខ្ញុំយំដល់ពេលមកវាភ្លៀងពេកបងជីដូនមួយនិង ខ្លាចខ្ញុំរងានិងក៏សុំផ្ទះគេក្បែរពុកឫស្សីនិងស្នាក់នៅនិងមួយប់ទៅបានមកវិញ ឆ្លងមកស្រុកនិងទៀតគាត់មកថ្ងៃចន្ទ័មីងក៏មកថ្ងៃចន្ទ័និងដែរ ប៉ុនគ្រាន់ថាមីងអត់បានឆ្លងមកភ្លៀងពេកគាត់ឆ្លងទៅវិញទៅមីងស្អែកឡើងថ្ងៃអង្គារនិងបានឆ្លងមកវិញ បានជ្រោះគ្នានិងថាស្តាយ៕

ក៖ កុំអីបានជូនគ្នាបាត់ហើយ

ខ៖ ចាស កុំអីបានជួបបងប្រុសបង្អស់និងបាត់

ក៖ ចុះអ្នកមីង តើអ្នកមីងនៅចាំផ្ទះរបស់អ្នកមីងកាលពីមុនមានលក្ខណះបែបណាដែរ?

ខ៖ ផ្ទះខ្ទមធ្វើទាបនៅនិងដី ដល់ក្រោយមកបានធ្វើផ្ទះធំតែធំនិងល្មមដែរទមិនសូវជាធំប៉ុន្មានដែរ ពីខ្ទងតែប្រកស្លឹក ផ្ទះមួយនៅនិងផ្ទះទាម៕

ក៖ អ្នកមីងតើជីវិតរបស់អ្នកមីងពេលណាខ្លះដែរអ្នកមីងគិតថាសប្បាយជាងគេដែរ?

ខ៖ ហឹមមានពេលណាសប្បាយទេមានតែពេលទុក្ខ ពិបាករឿងជីវភាពរស់នៅយើងរស់នៅតែម្នាក់ឯង រកស៊ីចិញ្ចឹមតែខ្លួនឯងអីតែខ្លួនឯង ដល់បេលតែថ្ងៃណាបុណ្យទានចូលឆ្នាំអីចឹងទៅ គេបបួលទោដើរលេងទៅចេះតែទៅជាមួយគេដើរមើលគេមើលឯងចឹងទៅ ទៅមើលគេអុំទូកអីចឹងទៅ មកវិញសប្បាយៃមួយគ្រាអីចឹងទៅ ដល់មកវិញនិងមានទុក្ខអីចឹងទៅ៕

កៈ នៅពេលដែរអ្នកមីងនៅពីក្មេងនិង តើអ្នកមីងធ្លាប់បានស្រមៃថាចង់ធ្វើអ្វីមួយនៅពេលធំឡើងដែរទេ?

ខៈ អត់មានស្រមៃអីផងអត់ទេ៕

កៈ ចឹងអ្នកមីងមានអ្វីផ្ដាំផ្ញើដល់កូនចៅជំនាន់ក្រោយដែរ អ្នកមីង?

ខៈ គ្រាន់តែផ្ដាំផ្ញើថា កុំអោយយើងធ្វើបាបឪពុកម្ដាយកុំជក់គ្រឿងញៀនគ្រឿងអីនិង វាមិនល្អខ្លួនទេជួនណាម្ដាយឪពុកអត់ចឹងទៅយើងក្មេងយើងត្រូវជាប់គុកហើយម្ដាយនៅឯនេះគាត់មិនពិបាក អានិងមានផ្លូវតែចឹងហើយបានថាកុំអោយក្មេងៗធ្វើចឹងវាមិនល្អខ្លួនទេត្រូវតែអាណិតឪពុកម្ដាយយើង កុំងោយឪពុកម្ដាយយើងពិបាកខ្លះទៅគេមានឪពុកម្ដាយគេមានគេចរតែទៅលួសកូនគេហើយ តែបើម៉ែឪយើងក្រមានតែខ្លួនយើងនិងហើយត្រូវតែជាប់គុក ហើយគ្មានអ្នកណាជាអ្នកបំផ្លាញខ្លួនយើងទេមានតែខ្លួនយើងនិងហើយដែរបំផ្លាញជីវិតខ្លួនឯងនោះ ចឹងាបនសូមអោយក្មេងៗជំនាន់ក្រោយទាំងអស់អោយជៀសវាងពីគ្រឿងញៀន ហើយលេងកីឡាអីចឹងទៅនិងបំបាត់គ្រឿងញៀននិងមានតែប៉ុននិងទេ៕

កៈ ចាស ចឹងខ្ញុំសូមអរគុណច្រើនដល់អ្នកមីង ដែរអ្នកមីងបានចំណាយពេលវេលាអោយក្មួយបានសម្ភាសពីជីវប្រវត្តិរបស់អ្នកមីង ហើយក្មួយនិងសុំថតរូបអ្នកមីងទុកជាអនុស្សាវរីយ ហើយថាតើអ្នកមីងអាចអនុញ្ញាតអោយក្មួយយកសម្លេងរបស់អ្នកមីងដាក់ចូលក្នុងគេហទំព័ររបស់ក្មួយបានដែរទេអ្នកមីង?

ខៈ ចាស បានតើ

កៈ ហើយខ្ញុំអ្នកសម្ភាស ហើយធ្វើឡើងនៅថ្ងៃទី៣ខែកញ្ញាឆ្នាំ២០១៨ នៅភូមិរនេះ ឃុំកោះដាច់ សង្កាត់ជ្រោយចង្វា រាជធានីភ្នំពេញ ចាសចឹងអរគុណច្រើនអ្នកមីង៕